**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៩២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅ នៃលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល ចុះមូលដ្ឋានរាជធានី ខេត្ត ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត ដែលហៅកាត់ថា "**លេខាធិការដ្ឋាន ក.រ.ម.**" ដើម្បីធ្វើជាសេនាធិការជូនរាជរដ្ឋាភិបាលកម្ពុជា លើសកម្មភាពរបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានតាមបណ្តារាជធានី ខេត្ត ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា។

**មាត្រា ២.-**

លេខាធិការដ្ឋាន ក.រ.ម. មានទីតាំងស្ថិតនៅក្នុងទីស្តីការក្រសួងមហាផ្ទៃ។

## ជំពូកទី២
## តួនាទី ភារកិច្ច

**មាត្រា ៣.-**

លេខាធិការដ្ឋាន ក.រ.ម. មានតួនាទីសម្របសម្រួលសកម្មភាពនានារបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីធានាឱ្យការបំពេញការងាររបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត គ្រប់លំដាប់ថ្នាក់ ទទួលបានលទ្ធផលល្អ ជាពិសេសការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការដោះស្រាយបញ្ហាប្រឈម សំណើ និងសំណូមពរនានា របស់ប្រជាពលរដ្ឋនៅមូលដ្ឋានប្រកបដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព។

**មាត្រា ៤.-**

លេខាធិការដ្ឋាន ក.រ.ម. មានភារកិច្ចសំខាន់ៗដូចខាងក្រោម៖

- ពិនិត្យ និងលើកយោបល់ជូន **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និង**រាជរដ្ឋាភិបាលកម្ពុជា** ដើម្បីពិនិត្យសម្រេចលើការស្នើសុំតែងតាំង និងផ្លាស់ប្តូរសមាសភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត
- ទទួលរបាយការណ៍ពីក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត ដើម្បីរៀបចំរបាយការណ៍បូកសរុប វាយតម្លៃអំពីលទ្ធផលការងារ និងបញ្ហាប្រឈម ដាក់ជូនរាជរដ្ឋាភិបាលកម្ពុជា ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ
- លើកយោបល់រៀបចំសេចក្តីណែនាំ និងគោលការណ៍នានាពាក់ព័ន្ធក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត ជូន **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និង**រាជរដ្ឋាភិបាលកម្ពុជា** ដើម្បីពិនិត្យ សម្រេច
- សហការសម្របសម្រួល ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលរាជធានី ខេត្ត ក្នុងការរៀបចំកិច្ចប្រជុំបូកសរុបប្រចាំឆ្នាំ របស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត
- លើកគម្រោងផែនការបណ្តុះបណ្តាលកសាងសមត្ថភាពដល់លេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត និងលេខាធិការដ្ឋានតាមក្រសួង ស្ថាប័ន លើការងាររៀបចំរបាយការណ៍ និងកិច្ចការនានារបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត
- សហការ និងគាំទ្រការអនុវត្តការងាររបស់លេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានតាមបណ្តារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ និងសង្កាត់
- ធ្វើបច្ចុប្បន្នភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត ជាទៀងទាត់ ដើម្បីពង្រឹងប្រសិទ្ធភាព ផ្តល់កិច្ចគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សម្របសម្រួលការងារប្រចាំថ្ងៃរបស់លេខាធិការដ្ឋាន ក.រ.ម. ស្របតាមការកំណត់ និងការសម្រេច របស់រាជរដ្ឋាភិបាលកម្ពុជា
- ធ្វើការងាររដ្ឋបាល ការងារបុគ្គលិក ភស្តុភារ គណនេយ្យរបស់លេខាធិការដ្ឋាន ក.រ.ម. តាមការកំណត់
- បំពេញការងារផ្សេងៗទៀតតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា និងតាមការណែនាំដោយផ្ទាល់ពី **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**។

## ជំពូកទី៣
## រចនាសម្ព័ន្ធ និងត្រា

**មាត្រា ៥.-**

លេខាធិការដ្ឋាន ក.រ.ម. ត្រូវដឹកនាំដោយប្រធាន០១រូប អមដោយអនុប្រធានមួយចំនួនតាមការចាំបាច់ជាជំនួយការ។

ប្រធានលេខាធិការដ្ឋាន ក.រ.ម. គឺជា រដ្ឋលេខាធិការ ០១រូប របស់ក្រសួងមហាផ្ទៃ។

អនុប្រធានប្រចាំការ នៃលេខាធិការដ្ឋាន ក.រ.ម. គឺជា អនុរដ្ឋលេខាធិការ ០១រូប របស់ក្រសួងមហាផ្ទៃ។

អនុប្រធានលេខាធិការដ្ឋាន ក.រ.ម. មានឋានៈ និងបុព្វសិទ្ធិស្មើអនុរដ្ឋលេខាធិការ។

ប្រធាន និងអនុប្រធានលេខាធិការដ្ឋាន ក.រ.ម. ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់**នាយករដ្ឋមន្ត្រី** តាមការស្នើសុំពី **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**។

ប្រធានលេខាធិការដ្ឋាន និងអនុប្រធានលេខាធិការដ្ឋាន ក.រ.ម. មានជំនួយការ០១រូប មានឋានៈស្មើអនុប្រធាននាយកដ្ឋាន និងត្រូវតែងតាំងដោយប្រកាសរបស់ក្រសួងមហាផ្ទៃ តាមសំណើរបស់ប្រធានលេខាធិការដ្ឋាន ក.រ.ម.។

**មាត្រា ៦.-**

លេខាធិការដ្ឋាន ក.រ.ម. ត្រូវបង្កើតត្រាមូលរបស់ខ្លួន ដើម្បីប្រើប្រាស់ក្នុងការអនុវត្តការងារប្រចាំថ្ងៃ។

លេខាធិការដ្ឋាន ក.រ.ម. មានសិទ្ធិប្រើប្រាស់ត្រារបស់ខ្លួន ដែលមានទម្រង់ដូចមានក្នុងឧបសម្ព័ន្ធ ស្តីពីគំរូត្រាមូលរបស់លេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត (ក.រ.ម.)។

**មាត្រា ៧.-**

លេខាធិការដ្ឋាន ក.រ.ម. មានអង្គភាពចំណុះ ចំនួន០៣ ដូចខាងក្រោម៖

- អង្គភាពរដ្ឋបាលសរុប
- អង្គភាពតាមដានត្រួតពិនិត្យវាយតម្លៃ
- អង្គភាពប្រតិបត្តិ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពចំណុះលេខាធិការដ្ឋាន ក.រ.ម. ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ។

**មាត្រា ៨.-**

អង្គភាពនីមួយៗ ត្រូវដឹកនាំដោយប្រធាន០១រូប អមដោយអនុប្រធានមួយចំនួនតាមការចាំបាច់ ព្រមទាំងមានសមាជិកមួយចំនួនជាជំនួយការ និងមានមន្ត្រីមួយចំនួន ដើម្បីជួយលើការងារប្រចាំថ្ងៃ។

ប្រធានអង្គភាពមានឋានៈ និងបុព្វសិទ្ធិស្មើអគ្គនាយករង អនុប្រធានអង្គភាពមានឋានៈ និងបុព្វសិទ្ធិស្មើប្រធាននាយកដ្ឋាន និងត្រូវតែងតាំងដោយអនុក្រឹត្យ តាមការស្នើសុំពី **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**។

សមាជិក នៃអង្គភាពនីមួយៗ មានឋានៈស្មើអនុប្រធាននាយកដ្ឋាន ត្រូវតែងតាំងដោយប្រកាសរបស់ក្រសួងមហាផ្ទៃ តាមសេចក្តីស្នើសុំពីប្រធានលេខាធិការដ្ឋាន ក.រ.ម.។

មន្ត្រី នៃអង្គភាពនីមួយៗ ជាមន្ត្រីជួយលើការងារប្រចាំថ្ងៃ ចាត់តាំងដោយលិខិតបង្គាប់ការរបស់ក្រសួងមហាផ្ទៃ តាមសេចក្តីស្នើសុំពីប្រធានលេខាធិការដ្ឋាន ក.រ.ម.។

**មាត្រា ៩.-**

ប្រធាន អនុប្រធានអង្គភាព សមាជិកអង្គភាព និងមន្ត្រី ដែលបម្រើការងារក្នុងអង្គភាពចំណុះ ត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រី នៃក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័ននានាតាមការចាំបាច់។

## ជំពូកទី៤
## របៀបរបបការងារ

**មាត្រា ១០.-**

ប្រធានលេខាធិការដ្ឋាន ក.រ.ម. ត្រូវរាយការណ៍ និងស្នើសុំយោបល់ពី **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ក្នុងការសម្របសម្រួលការងារជាមួយគ្រប់ក្រសួង ស្ថាប័ននានា និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា ១១.-**

លេខាធិការដ្ឋាន ក.រ.ម. ត្រូវសហការសម្របសម្រួលជាមួយ ក្រសួង ស្ថាប័ននានា និងរដ្ឋបាលរាជធានី ខេត្ត ដើម្បីគាំទ្រដល់កិច្ចដំណើរការប្រចាំថ្ងៃរបស់លេខាធិការដ្ឋាន ក.រ.ម.។

**មាត្រា ១២.-**

ប្រធានលេខាធិការដ្ឋាន ក.រ.ម. គឺជាប្រធានបុគ្គលិកទាំងអស់របស់លេខាធិការដ្ឋាន ក.រ.ម. រួមទាំង អនុប្រធានលេខាធិការដ្ឋាន ក.រ.ម. ប្រធាន អនុប្រធានអង្គភាព សមាជិក និងមន្ត្រីចំណុះលេខាធិការដ្ឋាន ក.រ.ម. ។

**មាត្រា ១៣.-**

អនុប្រធានលេខាធិការដ្ឋាន ក.រ.ម. ត្រូវបំពេញការងារតាមការចាត់ចែងរបស់ប្រធានលេខាធិការដ្ឋាន ក.រ.ម. ហើយត្រូវមានការទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះប្រធានលេខាធិការដ្ឋាន ក.រ.ម. និងអាចជំនួសប្រធានលេខាធិការដ្ឋាន ក.រ.ម. តាមឋានានុក្រម ក្នុងពេលប្រធានលេខាធិការដ្ឋាន ក.រ.ម. អវត្តមាន។

**មាត្រា ១៤.-**

ប្រធានអង្គភាពនីមួយៗ ត្រូវមានការទទួលខុសត្រូវអំពីកិច្ចការរបស់ខ្លួន និងមានគណនេយ្យភាពចំពោះប្រធានលេខាធិការដ្ឋាន ក.រ.ម.។

**មាត្រា ១៥.-**

សមាជិក និងមន្ត្រី ដែលបម្រើការងារក្នុងអង្គភាពចំណុះលេខាធិការដ្ឋាន ក.រ.ម. ត្រូវមានការទទួលខុសត្រូវអំពីកិច្ចការរបស់ខ្លួន និងមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រធានអង្គភាពរបស់ខ្លួន និងត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពតាមឋានានុក្រម ចំពោះប្រធានលេខាធិការដ្ឋាន ក.រ.ម.។

## ជំពូកទី៥
## អំពីថវិកា

**មាត្រា ១៦.-**

កញ្ចប់ថវិការបស់លេខាធិការដ្ឋាន ក.រ.ម. មានក្នុងកញ្ចប់ថវិកាដោយឡែករបស់ខ្លួនក្នុងក្រសួងមហាផ្ទៃ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា ១៧.-**

អនុក្រឹត្យលេខ៣៦អនក្រ.បក ចុះថ្ងៃពុធ ១កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃលេខាធិការដ្ឋានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានរាជធានី ខេត្ត ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា ត្រូវទុកជានិរាករណ៍ និងត្រូវជំនួសដោយអនុក្រឹត្យនេះ។

**មាត្រា ១៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១៤កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ មិថុនា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
**សម្តេចអគ្គមហាសេនាបតីតេជោ**
**នាយករដ្ឋមន្ត្រី** សូមហត្ថលេខា
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៩២ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១
ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល
ចុះមូលដ្ឋានរាជធានី ខេត្ត ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ
និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា

## គំរូត្រាមូល

## របស់លេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត ( ក.រ.ម.)




- ព្រះរាជាណាចក្រកម្ពុជា
  ទំហំអក្សរ : 22
  ប្រភេទអក្សរ : Limon R3
- ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត
  ទំហំអក្សរ : 20
  ប្រភេទអក្សរ : Limon R3
- រូបសញ្ញាចំកណ្តាល :
  . លេខាធិការដ្ឋាន
    ទំហំអក្សរ : 22
    ប្រភេទអក្សរ : Limon R3
  . ក. រ. ម.
    ទំហំអក្សរ : 30
    ប្រភេទអក្សរ : Limon R3